# គណៈកម្មាធិការសហប្រជាជាតិរកឃើញថា កម្ពុជាបរាជ័យ ក្នុងការគាំពារអ្នកការពារសិទ្ធិស្ត្រីនៅតាមជនបទ និងរំលោភបំពានសិទ្ធិរបស់ពួកគេ

ទីក្រុងហ្សឺណែវ (ថ្ងៃទី 27 ខែមិថុនា ឆ្នាំ២០២៣) – គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) របស់អង្គការសហប្រជាជាតិ បានរកឃើញថា កម្ពុជាខ្វះខាតវិធានការដើម្បីគាំពារអ្នកការពារសិទ្ធិស្ត្រីនៅតាមទីជនបទ ពីការបណ្តេញចេញដោយបង្ខំ និងការគំរាមកំហែងពីសំណាក់ក្រុមហ៊ុនអភិវឌ្ឍន៍ដីធ្លី ព្រមទាំងការចោទប្រកាន់ពីបទព្រហ្មទណ្ឌជាបន្តបន្ទាប់ និងការបៀតបៀនអំពីសំណាក់អាជ្ញាធរ ដែលរួមចំណែកដល់ការរំលោភបំពានសិទ្ធិជាច្រើនផ្សេងទៀត។

នៅថ្ងៃនេះ គណៈកម្មាធិការបានចេញសេចក្តីសម្រេចរបស់ខ្លួន បន្ទាប់ពីការពិនិត្យមើលបណ្តឹងមួយរបស់លោកស្រី X (ឈ្មោះក្លែងក្លាយ) ដែលឈរនៅជួរមុខនៃការតវ៉ាក្នុងវិវាទដីធ្លីមួយពាក់ព័ន្ធនឹងក្រុមហ៊ុន KDC អន្តរជាតិ ជាក្រុមហ៊ុនអភិវឌ្ឍន៍មួយដែលយកដីរបស់លោកស្រី X និងដីរបស់សហគមន៍។

Nahla Haidar សមាជិកគណៈកម្មាធិការ បានប្រាប់ឱ្យដឹងថា “ករណីនេះគូសបញ្ជាក់នូវលទ្ធភាពមិនស្មើភាពក្នុងការទទួលបានដី និងសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រីនៅតាមទីជនបទនៅកម្ពុជា”។ គាត់បន្ថែមទៀតថា “អស់រយៈពេលច្រើនជាងមួយទសវត្សហើយ លោកស្រី X ធ្វើការងារនេះដោយមិននឿយហត់ដើម្បីការពារសិទ្ធិដីធ្លីនៃសហគមន៍របស់គាត់ ថ្វីបើប្រឈមមុខនឹងការគំរាមកំហែង និងការសងសឹកពីក្រុមហ៊ុន KDC អន្តរជាតិ និងការប្រព្រឹត្តមិនស្មើភាពពីសំណាក់អំណាចតុលាការរបស់កម្ពុជាក្តី”។

លោកស្រី X រស់នៅក្នុងភូមិជនបទមួយ គឺភូមិឡពាង ឃុំតាជេស ខេត្តកំពង់ឆ្នាំង ប្រទេសកម្ពុជា ចាប់តាំងពីគាត់បានផ្លាស់ទីលំនៅមករស់នៅក្នុងភូមិនេះក្នុងឆ្នាំ២០០៤ ជាមួយប្តីរបស់គាត់។ ប្តីប្រពន្ធគាត់មានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់។

ក្នុងឆ្នាំ២០០៦ បុគ្គលិកមកពីក្រុមហ៊ុន KDC អន្តរជាតិ អមដំណើរដោយមន្ត្រីនគរបាល ប៉ុន្តែគ្មានភស្តុតាងអំពីកម្មសិទ្ធិភាពឡើយ បានជីកប្រឡាយជុំវិញដីសហគមន៍ និងរារាំងដល់និវាសនជនចំនួន១៤គ្រួសារមិនឱ្យធ្វើស្រែចំការ និងចូលទៅផ្ទះរបស់ពួកគេបាន។ ក្នុងឆ្នាំ២០០៨ ដោយគ្មានការជូនដំណឹងជាមុន បុគ្គលិករបស់ក្រុមហ៊ុន KDC អន្តរជាតិ បានបំផ្លាញផ្ទះនៅក្នុងភូមិ និងដីស្រែជុំវិញ រួមទាំងផ្ទះរបស់លោកស្រី X និងប្តីផងដែរ។ ឯកសារកម្មសិទ្ធិដីធ្លីរបស់គ្រួសារគាត់បាត់បង់នៅពេលនោះ។

លោកស្រី X ត្រូវបាននគរបាលទទួលបន្ទុក សួរចម្លើយពីបទញុះញង់ឱ្យមានអំពើហិង្សានៅក្នុងអំឡុងពេលតវ៉ា តាមរយៈបណ្តឹងពីក្រុមហ៊ុន KDC អន្តរជាតិ។ ភ័យខ្លាចនូវការចាប់ខ្លួន លោកស្រី X និងគ្រួសាររបស់គាត់បានភៀសខ្លួនទៅប្រទេសថៃ ប៉ុន្តែបានវិលត្រលប់មកកម្ពុជាវិញទាំងបង្ខំ ហើយគាត់បន្តការពារផលប្រយោជន៍សហគមន៍របស់គាត់។ ក្នុងឆ្នាំ២០១៣ មានលិខិតអនាមិកគំរាមសម្លាប់មួយបិទនៅជញ្ជាំងផ្ទះរបស់គាត់។ ក្នុងឆ្នាំ២០១៤ បុគ្គលិករបស់ក្រុមហ៊ុន KDC អន្តរជាតិធ្វើរបងហ៊ុំព័ទ្ធដីជាទ្រព្យរបស់លោកស្រី X ទំហំ ១,៥

ហិកតា។ ដីដែលបានហ៊ុំព័ទ្ធដោយក្រុមហ៊ុន KDC នៅតែមិនមានការអភិវឌ្ឍចាប់តាំងពីពេលនោះមក។ ក្នុងឆ្នាំ២០១៧ តុលាការបានកោះហៅលោកស្រី X ពាក់ព័ន្ធនឹងសំណុំរឿងបរិហាកេរ្តិ៍ ដោយគាត់មិនដឹងអំពីមូលដ្ឋានពិតប្រាកដចំពោះការចោទប្រកាន់លើលោកស្រីនោះឡើយ។

ដោយសារគ្មានការឆ្លើយតបលើញត្តិជាច្រើនរបស់គាត់នៅមុខតុលាការនានានៅកម្ពុជា លោកស្រី X នាំករណីនេះមកកាន់គណៈកម្មាធិការ ដោយអះអាងថា សិទ្ធិរបស់គាត់នៅក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ រងការរំលោភបំពាន។

ស្របពេលសម្តែងនូវការសោកស្តាយ ដោយមិនបានទទួលសេចក្តីសង្កេតនានាពីរដ្ឋភាគី គណៈកម្មាធិការបានចាត់ទុក អាជ្ញាធរកម្ពុជាបរាជ័យក្នុងការធានាថា ក្រុមហ៊ុន KDC អន្តរជាតិមិនរើសអើងចំពោះលោកស្រី X និងមិនបានចាត់វិធានការ ដើម្បីការពារលោកស្រី X ពីអំពើហិង្សាទៅលើគាត់ពីសំណាក់ក្រុមហ៊ុនអភិវឌ្ឍន៍នេះឡើយ។

គណៈកម្មាធិការបានសង្កត់ធ្ងន់ថា ការបណ្តេញចេញដោយបង្ខំមិនមែនជាបាតុភូតដែលមានភាពអព្យាក្រឹតយេនឌ័រទេ ប៉ុន្តែប៉ះពាល់មិនមានសមាមាត្រដល់ស្ត្រី។ Haidar ថ្លែងថា “ក្នុងនាមជាស្ត្រីនៅជនបទ ជាអ្នកការពារសិទ្ធិមនុស្ស និងជាម្តាយ ជីវិតរបស់លោកស្រី X បានធ្លាក់ចុះនៅក្នុងអំឡុងពេលនៃដំណើរការការពារដីរបស់គាត់។ បន្ថែមលើការបាត់បង់ទ្រព្យ និងផ្ទះសម្រាប់កូនៗរបស់គាត់ គាត់ក៏មិនអាចបន្តធ្វើការងារជាគ្រូបង្រៀន និងរងការបង្ខំឱ្យផ្លាស់ទីលំនៅទៅកាន់ទីកន្លែងមួយ ដែលខ្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជា អនាម័យជាដើម”។

គណៈកម្មាធិការបានកំណត់ថា កម្ពុជាបន្តបរាជ័យចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងការប្រតិបត្តិតាមបទប្បញ្ញត្តិនានានៃអនុសញ្ញា ពាក់ព័ន្ធនឹងការពិចារណាលើបញ្ហាជាក់លាក់ ដែលស្ត្រីនៅជនបទបានជួបប្រទះ និងតួនាទីសំខាន់ៗរបស់ស្ត្រីនៅជនបទក្នុងការផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចនៃគ្រួសាររបស់ពួកគេ និងធានានូវសិទ្ធិរបស់ពួកគេដើម្បីចូលរួមក្នុងការរៀបចំផែនការ និងការអភិវឌ្ឍដីធ្លី។

គណៈកម្មាធិការក៏បានរកឃើញថា ដំណើរការអនុវត្តនីតិវិធីរបស់រដ្ឋភាគីប្រឆាំងនឹងលោកស្រី X បានរួមចំណែកដល់ការសងសឹកក្រៅផ្លូវច្បាប់ចំពោះភាពជាសកម្មជនរបស់គាត់ ដែលរារាំងគាត់បន្តការពារផលប្រយោជន៍សហគមន៍របស់គាត់។

គណៈកម្មាធិការបានស្នើឱ្យ កម្ពុជាផ្តល់សំណងពេញលេញដល់លោកស្រី X ធានាថា គាត់មានសិទ្ធិពេញលេញទទួលបានដីធ្លី និងមានការការពារផលប្រយោជន៍នៃសហគមន៍របស់គាត់ដោយសុវត្ថិភាព និងដោយសេរី។ គណៈកម្មាធិការក៏ស្នើឱ្យកម្ពុជាធានាថា ការទទួលបានដីនៅជនបទសម្រាប់សម្បទានសេដ្ឋកិច្ច និងសម្បទានដទៃទៀត អនុវត្តទៅតាមដំណើរការត្រឹមត្រូវ រួមទាំងការព្រមព្រៀងដោយសេរី ជាមុននិងដោយមានព័ត៌មានគ្រប់គ្រាន់ និងពិនិត្យឱ្យបានម៉ត់ចត់ និងមិនលម្អៀងលើការទាមទារកម្មសិទ្ធិភាព ដែលធ្វើឡើងដោយស្ត្រី។

ចប់

***សម្រាប់ព័ត៌មានបន្ថែម និងសំណើសម្រាប់ប្រព័ន្ធផ្សព្វផ្សាយនៅទីក្រុងហ្សឺណែវ សូមទាក់ទង៖***
*Vivian Kwok តាមអាសយដ្ឋានអ៊ីម៉េល vivian.kwok@un.org ឬ*
*ផ្នែកផ្សព្វផ្សាយនៃការិយាល័យសិទ្ធិមនុស្សសហប្រជាជាតិ នៅ ohchr-media@un.org*

***សាវតារ៖***
*គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ តាមដានត្រួតពិនិត្យភាពអនុលោមរបស់រដ្ឋភាគីចំពោះ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលមកទល់នឹងពេលបច្ចុប្បន្នមានរដ្ឋភាគីចំនួន ១៨៩។ គណៈកម្មាធិការមានសមាជិកចំនួន ២៣នាក់ ដែលជាអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យនៅក្នុងវិស័យសិទ្ធិស្ត្រី មកពីជុំវិញពិភពលោក ដែលបម្រើការងារក្នុងសមាសភាពរៀងៗខ្លួនរបស់ពួកគេ និងមិនតំណាងឱ្យរដ្ឋភាគីឡើយ។*

*ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ អនុញ្ញាតឱ្យ គណៈកម្មាធិការនេះទទួល និងពិនិត្យបណ្តឹងនានារបស់បុគ្គល ឬក្រុមនៃបុគ្គលទាំងឡាយ ដែលនៅក្រោមយុត្តាធិការរបស់រដ្ឋភាគីនៃពិធីសារបន្ថែម ដែល អះអាងថាខ្លួនជាជនរងគ្រោះនៃការរំលោភបំពានសិទ្ធិណាមួយនៅក្នុងចំណោមកម្រងសិទ្ធិ ដែលមានចែងនៅក្នុងអនុសញ្ញា។ មកទល់ពេលបច្ចុប្បន្ន រដ្ឋចំនួន ១១៥ បានផ្តល់សច្ចាប័ន ឬចូលជាសមាជិកពិធីសារបន្ថែមនេះ។ ទស្សនៈ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការទៅលើទំនាក់ទំនងនីមួយៗ គឺជាការវាយតម្លៃដោយឯករាជ្យទៅលើភាពអនុលោមរបស់រដ្ឋតាមកាតព្វកិច្ចរបស់ពួកគេពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅក្រោមអនុសញ្ញា។*